ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

តុលាការកំពូល

សភាផ្នែក រដ្ឋប្បវេណី

សំណុំរឿង រដ្ឋប្បវេណី

លេខ : ២១៣

ចុះថ្ងៃទី០៥ខែសីហាឆ្នាំ១៩៩៩

សាលដីកា

លេខ : ២០៦

ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០០

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ :

១_ ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២_ លោក ប៉ែន ស៊ុន ជាចៅក្រម

៣_ លោក ជីវ កេង ជាចៅក្រម

៤_ លោក ស៊ុន ឌឹម ជាចៅក្រម

៥_ លោក ឈឹម ស៊ីផល ជាចៅក្រមរបាយការណ៍

ជំនួស លោក សោម សិរីវឌ្ឍ

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

លោក ប៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៣០៤ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៩១ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះទឹម ហ៊ឹង អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅ ភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

មានមេធាវី លោក ទូត លុច

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះជុន ទៀងងាន អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅ ភូមិកណ្តាល ឃុំ.ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ឈ្មោះ ជុន ទៀងងាន បានផ្ទេរសិទ្ធិអោយឈ្មោះ ឈុប បុរាណ

មានមេធាវី អ្នកស្រី ពីង ធីតា

តាមបណ្តឹងសាទុក្ខលេខ ២០៥ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ទឹម ហ៊ឹង បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ៣០៤ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

--- ---

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២១៣ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៨៩ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០២.៦.៨៨ របស់ដើមចោទឈ្មោះ ទឹម ហ៊ីង បានបញ្ជាក់ថា : ខ្លួនប្ដឹងទាមទារសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋានទំហំ ៨ , ១០ម គុណ ២២ម ដែលស្ថិតនៅភូមិកណ្ដាល ឃុំព្រះនេត្រព្រះ មកគ្រប់គ្រងវិញ ដោយហេតុថា ដីនេះជាដីរបស់ខ្លួន ហើយត្រូវឈ្មោះ វ៉ុយ គីមឡាយ និង ឈ្មោះ ជុន វៀងាន សុំធ្វើរោងវីដេអូរ ហើយសព្វថ្ងៃនេះមិនព្រមរុះរើចេញទេ ។

បានឃើញសាលក្រមលេខ ១០៩ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ១៩៨៨ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០២.៦.១៩៨៨ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលពាក្យបណ្ដឹងនៅពេលសវនាការរបស់ចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ចែកដីទំនាស់ដែលនៅភូមិកណ្ដាល ឃុំព្រះនេត្រព្រះ ជាពីរចំណែកស្មើគ្នា ដោយអោយដើមចោទយកចំណែកខាងលិចជាប់ដីទឹម ឌូវ ហើយអោយចុងចម្លើយយកដីចំណែកខាងកើត ជាប់ដីរ៉ុត ឆេង នៅពេលសាលក្រមនេះចូលជាស្ថាពរ ហើយមានអនុភាពអនុវត្ត ។

៤- អោយដើមចោទ និង ចុងចម្លើយ រួមគ្នាបង់ប្រាក់ប្រដាប់ក្ដី ៧.០០០រៀល និង បង់ពន្ធសមាមាត្រមួយភាគរយលើដីទំនាស់គឺ ១០.០០០រៀល "មួយម៉ឺនរៀល" ។

៥- សាលក្រមនេះជំនុំជំរះ ចំពោះមុខគូភាគី ហើយបើកសិទ្ធិអោយតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៨៩ របស់អ្នកស្រី ជុន វៀងាន ដែលប្ដឹងជំទាស់នឹងសាលក្រមលេខ ១០៩ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ១៩៨៨ របស់តុលាការខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីកាលេខ ៣០៤ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧.០១.៨៩ របស់ឈ្មោះ ជុន វៀងាន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១០៩ ចុះថ្ងៃទី ២២.១២.៨៨ របស់តុលាការខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ។

៣- ប្រគល់ដីទំនាស់ស្ថិតនៅភូមិកណ្ដាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ អោយទៅឈ្មោះ ជុន វៀងាន កាន់កាប់ជាកម្មសិទ្ធិតទៅ និងអោយឈ្មោះ ទឹម ហ៊ីង និង ក្រុមគ្រួសារ រុះរើសំណង់ផ្សេងៗរបស់ខ្លួនចេញពីដីទំនាស់នេះនៅពេល

--- ---

សាលដីកាចូលជាស្ថាពរ ។

៤_ គាត់យកប្រាក់ប្រដាប់ក្ដីដាក់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលដើមបណ្ដឹងបានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង លើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ និង បង្គាប់អោយឈ្មោះ ទឹម ហ៊ុង បង់ពន្ធសមាមាត្រ ១ភាគរយ លើថ្លៃដីទំនាស់ ដែលបានជាប្រយោជន៍ថវិការដ្ឋ ៨០ភាគរយ និង រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ

៥_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញពាក្យបណ្ដឹងសាទុក្ខលេខ ២០៥ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ទឹម ហ៊ុង បានប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចនៃសាលដីកាលេខ ៣០៤ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ១៩៩៩របស់អ្នកស្រី ទឹម ហ៊ុង ។

បានឃើញសារណាតបចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ១៩៩៩របស់អ្នកស្រីជុន ទៀងងាន

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណី លេខ ៣០៤ ចុះថ្ងៃទី ១៤.៦.៩៩ របស់សាលាឧទ្ធរណ៍សំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ។

បានស្ដាប់ចម្លើយរបស់អ្នកស្រី ទឹម ហ៊ុង ជាដើមចោទ និង ជាម្ចាស់បណ្ដឹងសាទុក្ខ ដែលបានឆ្លើយនៅពេលសវនាការថា : ឆ្នាំ ១៩៧៩ ដីនេះឈ្មោះ វុយ គីមឡាយ ត្រូវជាបងថ្លៃរបស់ខ្លួន គាត់បានកាន់កាប់តែម្នាក់ឯងរួមនឹងខ្លួនជាក្រុមគ្រួសារ រៀបចំបង្កើតរោងម៉ាស៊ីនកិនស្រូវតូចមួយធ្វើអាជីវកម្មជាមួយគ្នាគ្រាន់នឹងបានដោះស្រាយជីវភាព ។ ក្រោយមកដោយម៉ាស៊ីនកិនស្រូវនៅកៀនផ្ទះពេកបងខ្លួន និង ក្រុមគ្រួសារបានសំរេចរើរោងម៉ាស៊ីននេះទៅធ្វើកន្លែងផ្សេងវិញ ។ នៅឆ្នាំ ១៩៨១_៨៥ បងថ្លៃខ្លួន និង ក្រុមគ្រួសារបានធ្វើរោងបញ្ចាំងវីដេអូ ពេលនោះ ជុន ទៀងងាន បានទំនាក់ទំនងជាមួយគ្រួសារខ្លួន ដើម្បីសុំចូលភាគហ៊ុនជាមួយផង ដោយគាត់មានផ្ទះចាស់មួយរុះរើយកឈើ និង ក្រឿងផ្ទះនោះមកដាក់ហ៊ុនសង់រោង ត្រឹមតែជាគ្រោងឆ្អឹងរោងតែប៉ុណ្ណោះ រីឯក្រឿងប្រក់ និង ជញ្ជាំង ព្រមទាំងម៉ាស៊ីនភ្លើង អេក្រង់វីដេអូ ប្រដាប់ប្រដាសំរាប់ធ្វើអាជីវកម្ម គឺជាចំណែកហ៊ុនរបស់បងខ្លួន និង ក្រុមគ្រួសារខ្លួនទាំងអស់ ។

បានស្ដាប់ចម្លើយរបស់លោក ឈុប បុរាណ ជាចុងចម្លើយ និង ជាចុងបណ្ដឹងសាទុក្ខ ដែលបានឆ្លើយនៅពេលសវនាការថា : ដីទំនាស់នេះនៅឆ្នាំ ១៩៧៩ មីងរបស់ខ្លួនឈ្មោះ ជុន ទៀងងាន បានកាន់កាប់ថែរក្សារហូតមកទល់បច្ចុប្បន្ននេះហើយ ដីទំនាស់នេះគឺជាដីដែល

--- ---

នៅចំពីមុខផ្ទះរបស់មឹងខ្លួន  បើនិយាយអោយចំគឺជាដីមុខផ្ទះតែម្តងនៅលើដីនេះកន្លងមកមឹងខ្លួន
បានដាក់អុសគរជាគំនរ  សំរាប់ប្រើប្រាស់ចងគោ  ក្របី  និងដាក់រទេះ និង ជាផ្លូវសំរាប់
ដើរ នៅក្នុងឆ្នាំ ១៩៨២ ឈ្មោះ វ៉ុយ គឹមឡុយ ត្រូវជាបងរបស់ ទឹម ហ៊ឹង បានបបួលមឹងខ្លួនសង់រោង
វីដេអូរកស៊ីចូលហ៊ុនគ្នាពីរនាក់  ក្នុងការចូលហ៊ុននេះមឹងរបស់ខ្លួនមានដី និង បានរុះផ្ទះមួយខ្នងមកសង់
រោងវីដេអូ  ចំណែកឈ្មោះ វ៉ុយ គឹមឡុយ ចេញឬស្សីចំនួន ៧០ដើម ស្បូវចំនួន ២.០០០កណ្តាប់
និងចេញឧបករណ៍បញ្ចាំងវីដេអូ  ពេលបានចំណេញគឺចែកគ្នាស្មើ ៗ  នៅឆ្នាំ ១៩៨៧ ឈ្មោះ
ទឹម ហ៊ឹង បានសង់តូបលក់ចាប់ហួយកប៊ិកកប៊ុក នៅពីមុខរោងវីដេអូ  ដោយយល់ថាអ្នកជិតខាងមឹងខ្លួន
ក៏យោគយល់ ក៏អោយលក់ដើម្បីគ្រាន់បានដោះស្រាយជីវភាពគ្រួសារ  ប៉ុន្តែឈ្មោះ ទឹម ហ៊ឹង បែរ
ជាមានគំនិតចង់បានដីរបស់មឹងខ្លួន ទៅវិញ ៗ

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ទួត លុច ការពារអោយអ្នកស្រី ទឹម ហ៊ឹង
ជាដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខ ថា :  ទោះបីជាពុំមានការផ្ទេរសិទ្ធិពីម្តាយមកអោយ
កូនក្តីខ្លួនក៏ដោយ  ក៏នៅតុលាការថ្នាក់ក្រោមអ្នកទាំងពីរបានបញ្ជាក់ថា  គាត់បានប្រគល់ដីនេះ
អោយឈ្មោះ ទឹម ហ៊ឹង រួចទៅហើយ  ដូច្នេះអ្នកស្រី ទឹម ហ៊ឹង មានសិទ្ធិគ្រប់គ្រាន់ក្នុងការប្តឹង
ទាមទារដីទំនាស់នេះ  ៗ  នៅឆ្នាំ ១៩៨០ ទឹម ហ៊ឹង មករស់នៅជាមួយម្តាយ និង បងនៅ
ឆ្នាំ ១៩៨០_៨២ បងរបស់អ្នកស្រី ទឹម ហ៊ឹង ធ្វើរោងម៉ាស៊ីនកិនស្រូវមួយ ៗ   នៅឆ្នាំ១៩៩០
ទឹម ហ៊ឹង រៀបការ  ម្តាយ ទឹម ហ៊ឹង ចែកដីអោយគាត់ ៗ នៅតុលាការពុំមានសាក្សីណាម្នាក់
ស្បថជូនតុលាការទេ  ៗ

បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី ពឹង ធីតា ការពារអោយលោក
ឈុប បូរាណ ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ ថា :  ដីទំនាស់នេះស្ថិតនៅចំពីមុខផ្ទះ
ជុន វ៉ិទ្ធានី គ្រប់គ្រងតាំងពីឆ្នាំ ១៩៧៩ ដោយបានដាក់អុស  ដាក់រទេះ  ចងគោ ក្របី
នៅទីនោះ ៗ  នៅឆ្នាំ ១៩៨២ បើករោងវីដេអូ ដោយមានបងរបស់ ទឹម ហ៊ឹង សុំចូលភាគ
ហ៊ុន ៗ ឆ្នាំ ១៩៨៧ ទឹម ហ៊ឹង បានសង់រោងចូលលើដីទំនាស់នេះ  បញ្ហានេះអ្នកស្រុក អ្នកភូមិគេ
យោគយល់គ្នា សុខចិត្តអោយឈ្មោះ ទឹម ហ៊ឹង សង់រោងស្នាក់នៅជាបណ្តោះអាសន្ន  នៅមិនទាន់
បានមួយឆ្នាំផងឈ្មោះ ទឹម ហ៊ឹង បានដកបង្គោលដោយដោះដូរដាក់បង្គោលថ្មីជំនួស  ក៏កើតមាន
ទំនាស់ឡើង  ៗ បញ្ហាម៉ាស៊ីនស្រូវពុំមានពាក់ព័ន្ធ នឹង ដីទំនាស់ទេ  ហើយនៅបច្ចុប្បន្នចំពោះ
ផ្ទះរបស់កូនក្តីខ្លួន មានផ្លូវដើរចេញទៅថ្នល់ហើយផ្ទះនេះសង់តាំងពីសង្គមចាស់ហើយ  មានទីតាំង
នៅពីមុខផ្ទះដែរ ៗ ចំណែករបងធ្វើក្រោយរោងវីដេអូ គ្រាន់ទុកការពារក្មេងកុំអោយលប
មើលតែប៉ុណ្ណោះ  ៗ

រឿងដីនោះកូនក្តីខ្លួនបានគ្រប់គ្រងតាំងពីឆ្នាំ ១៩៧៩_៨៨ មកម្លេះ ហើយ
ទោះបីគាត់ទើបសុំនៅឆ្នាំ ១៩៨៨ ក៏ដោយក៏ពុំតាមផ្លូវច្បាប់ដែរ  ៗ

សំណូមពរសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ៗ

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីនៃគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ២០៥ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី ទឹម ហ៊ីង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចទទួលយករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់អោយទៅអ្នកស្រី ជុន ទៀងងាន ដោយអាងហេតុថា អ្នកស្រីរូបនេះបានកាន់កាប់តាំងពីឆ្នាំ១៩៧៩មកហើយ អ្នកស្រីមានសិទ្ធិតាមមាត្រា ៦២ និង ៧៤ នៃច្បាប់ភូមិបាល និង តាមអនុក្រឹត្យលេខ ២៥អនក្រ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៨៩នោះជាការពុំត្រឹមត្រូវទេពីព្រោះតុលាការខេត្ត ក៏ ដូចជាសាលាឧទ្ធរណ៍ ពុំបានចាត់អោយមន្ត្រីជំនាញសុរិយោដីធ្វើការគូរប្លង់ និង វាយតម្លៃអោយបានច្បាស់ អំពីរោងម៉ាស៊ីនកិនស្រូវ តើនៅលើដីទំនាស់ ឬ នៅខាងក្បែរផ្ទះឈាយ សោម ម្យ៉ាងទៀតសាលាឧទ្ធរណ៍ក៏ពុំទាន់បានស៊ើបអង្កេតអំពីបង្គោលរបងពីលិចទៅកើត ចន្លោះផ្ទះ ជុន ទៀងងាន និង រោងវីដេអូរ តើជារបងខណ្ឌព្រំដី ឬ ជារបងអ្វី ។

- យល់ឃើញថា : សាលដីការឧទ្ធរណ៍លេខ ៣០៤ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ២០៥ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី ទឹម ហ៊ីង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការឧទ្ធរណ៍លេខ ៣០៤ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

--- ---

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២១៣ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ទៅ សាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ទឹម ហ៊ឹង បានបង់ទុកនៅតុលាការកំពូលគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការរឹបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវអោយអ្នកស្រី ជុន ចេញងាលសងប្រាក់ ១៧.០០០រៀល នេះ ទៅអ្នកស្រី ទឹម ហ៊ឹង វិញ ។

៥_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០០ ។